## ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**សាលាដំបូងខេត្តសៀមរាប**

**សាលក្រមព្រហ្មទណ្ឌ**
**លេខៈ ៤៥(ច)/៤៤៧**
ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០២២
-សំណុំរឿងព្រហ្មទណ្ឌលេខៈ ៣២៣
ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០២២
-សំណុំរឿងជំនុំជម្រះលេខៈ ៣១៧
ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០២២

## តាងនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងខេត្តសៀមរាប

បានបើកសវនាការជំនុំជម្រះជាសាធារណៈ សាលសវនាការលេខ ក១ អគារក នៃសាលាដំបូងខេត្តសៀមរាប នាថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០២២ វេលាម៉ោង ពីរ និងសាមសិបនាទីរសៀល ដែលមានសមាសភាពចូលរួមដូចតទៅ:

**<u>ចៅក្រមជំនុំជម្រះ</u>**

លោកស្រី [redacted] ឋានៈចៅក្រម ជាចៅក្រមជំនុំជម្រះ

**<u>តំណាងអយ្យការ</u>**

លោក [redacted] ព្រះរាជអាជ្ញារង អមសាលាដំបូងខេត្តសៀមរាប

**<u>ក្រឡាបញ្ជីសវនាការ</u>**

លោក [redacted] ក្រឡាបញ្ជីសាលាដំបូង

ដើម្បីជំនុំជម្រះលើ ៖ សំណុំរឿងព្រហ្មទណ្ឌលេខៈ ៣២៣ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០២២ ដែលមានជនជាប់ចោទៈ

១- ឈ្មោះ [redacted] សុភាត់ ឬ [redacted] សុផាត់ ហៅ យួន ភេទប្រុស ថ្ងៃខែឆ្នាំកំណើត ០៥.១២.១៩៩៧ ជនជាតិខ្មែរ ទីកន្លែងកំណើតនៅ [redacted] ខេត្តសៀមរាប ទីលំនៅមុនពេលឃាត់ខ្លួនភូមិ [redacted] ខេត្តសៀមរាប កាន់សាសនាព្រះពុទ្ធ កម្រិតវប្បធម៌ថ្នាក់ទី០៩ មុខរបរគ្មាន នៅលីវ ឪពុកឈ្មោះ [redacted] សុផាន (រ) ម្តាយឈ្មោះ [redacted] សារ៉ែន (រ) ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការ គ្មាន ។ (ក្នុងឃុំ)

ឃុំខ្លួនតាមដីកាបង្គាប់ឲ្យឃុំខ្លួនលេខ ១៦៥យខ/ប ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០២២។

២-ឈ្មោះ [redacted] សំ ហៅ នួន ភេទប្រុស ឆ្នាំកំណើត១៩៩៩ ជនជាតិខ្មែរ ទីកន្លែងកំណើតនៅភូមិ [redacted] ខេត្តសៀមរាប ទីលំនៅមុនពេលឃាត់ខ្លួនភូមិ [redacted] ខេត្តសៀមរាប កម្រិតវប្បធម៌ថ្នាក់ទី០៥ មុខរបរកម្មករសំណង់ ឪពុកឈ្មោះ [redacted] សេង (ស) ម្តាយឈ្មោះ [redacted] ណាត (រ) ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការ គ្មាន ។ (ក្នុងឃុំ)

ឃុំខ្លួនតាមដីកាបង្គាប់ឲ្យឃុំខ្លួនលេខ ១៦៦យខ/ប ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០២២។



Scanned with CamScanner

ជាប់ចោទពីបទ រក្សាទុក និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិតាកុះ ឃុំព្រះដាក់ ស្រុកបន្ទាយស្រី ខេត្តសៀមរាប កាលពីថ្ងៃទី០៩ ខែមីនា ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌ មានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៤០ កថាខណ្ឌទី១ និងទី៤ និងមាត្រា៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

៣-ឈ្មោះ [redacted] ស្រា ហៅ ត្រា ភេទប្រុស អាយុ២២ឆ្នាំ ជនជាតិខ្មែរ ទីកន្លែងកំណើតនៅភូមិ [redacted] ខេត្តសៀមរាប ទីលំនៅបច្ចុប្បន្ននៅភូមិតាឯក ឃុំរុនតាឯក ស្រុកបន្ទាយស្រី ខេត្តសៀមរាប កម្រិតវប្បធម៌ថ្នាក់ទី០៣ មុខរបរកម្មករសំណង់ នៅលីវ ឪពុកឈ្មោះ [redacted] ហេង (រ) ម្តាយឈ្មោះ [redacted] សំ (រ) ។ (គេចខ្លួន)

ជាប់ចោទពីបទ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិតាកុះ ឃុំព្រះដាក់ ស្រុកបន្ទាយស្រី ខេត្តសៀមរាប កាលពីថ្ងៃទី០៨ ខែមីនា ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៤០ កថាខណ្ឌទី៣ និងទី៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

**អង្គហេតុកើតឡើងមានដូចតទៅ:**

កាលពីថ្ងៃទី០៩ ខែមីនា ឆ្នាំ២០២២ វេលាម៉ោង ០៩ និង ០០នាទី នៅចំណុចភូមិតាកុះ ឃុំព្រះដាក់ ស្រុកបន្ទាយស្រី ខេត្តសៀមរាប កម្លាំងការិយាល័យប្រឆាំងគ្រឿងញៀន បានសហការជាមួយកម្លាំងផ្នែកប្រឆាំងគ្រឿងញៀន នៃអធិការនគរបាលស្រុកប្រាសាទបាគង និងកម្លាំងផ្នែកប្រឆាំងគ្រឿងញៀន នៃអធិការនគរបាលស្រុកបន្ទាយស្រី បានធ្វើការឃាត់ខ្លួនឈ្មោះ [redacted] សុភាត់ ឬ [redacted] សុផាត់ ហៅ យួន ផែកឆេរ និងដកហូតបានគ្រឿងញៀនចំនួន ០១កញ្ចប់ ទម្ងន់ ០,១(សូន្យក្បៀសមួយ)ក្រាម ។ បន្ទាប់មកឈ្មោះ [redacted] សុភាត់ ឬ [redacted] សុផាត់ បានសហការជាមួយសមត្ថកិច្ចបន្តធ្វើការឃាត់ខ្លួនបក្សពួកបានចំនួន ០១នាក់បន្ថែមទៀត ឈ្មោះ [redacted] សំ ហៅ នួន ព្រមទាំងបានដកហូតគ្រឿងញៀនចំនួន ០១កញ្ចប់ ទម្ងន់ ០,៥(សូន្យក្បៀសប្រាំ)ក្រាម និងសម្ភារៈវេចខ្ចប់គ្រឿងញៀនមួយចំនួន ។ ពេលឃាត់ខ្លួនឈ្មោះ [redacted] សំ ហៅ នួន បានឆ្លើយថា គ្រឿងញៀនដែលសមត្ថកិច្ចដកហូត គឺគាត់ទិញពីឈ្មោះ [redacted] ស្រា ហៅ ត្រា កាល់ពីថ្ងៃទី០៨ ខែមីនា ឆ្នាំ២០២២ ។ បន្ទាប់មកសមត្ថកិច្ចបានធ្វើតេស្តទឹកនោមស្វែងរកសារធាតុញៀនលើឈ្មោះ [redacted] សុភាត់ ឬ [redacted] សុផាត់ ហៅ យួន និងឈ្មោះ [redacted] សំ ហៅ នួន ជាលទ្ធផល គឺវិជ្ជមានទាំងពីរនាក់ ។

បានឃើញ: របាយការណ៍សំយោគលេខ ២៤៦/២២ ប្រ.គ្រ.ញ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០២២ របស់ការិយាល័យប្រឆាំងគ្រឿងញៀន នៃស្នងការដ្ឋាននគរបាលខេត្តសៀមរាប ។

បានឃើញ: ដីកាសន្និដ្ឋានស្ថាពរលេខ: ៣០៨អយក/២២ ចុះថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០២២ របស់តំណាងអយ្យការអមសាលាដំបូងខេត្តសៀមរាប ។

បានឃើញ: ដីកាដំណោះស្រាយ លេខ: ២១៩៥(ឋ)/២២ ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ២០២២ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តសៀមរាប ។

**នាពេលសវនាការ**

- ជនជាប់ចោទឈ្មោះ [redacted] សុភាត់ ឬ [redacted] សុផាត់ ហៅ យួន បានឆ្លើយថា ៖ សមត្ថកិច្ចឃាត់ខ្លួននៅថ្ងៃទី០៩ ខែមីនា ឆ្នាំ២០២២ វេលាម៉ោងប្រហែល ១១ និង ០០នាទី ពេលដែលខ្លួនជិះម៉ូតូយកថ្នាំ

ញៀនទៅលក់ឲ្យមនុស្សប្រុសម្នាក់មិនស្គាល់ឈ្មោះជាអ្នកបើកឡានដឹកដីនៅចំណុចរង្វង់មូលតាកុះ ។ ពេលកំពុងជិះម៉ូតូតាមផ្លូវ ខ្លួនបានជួបនឹងសមត្ថកិច្ច ទើបខ្លួនជិះម៉ូតូត្រឡប់ក្រោយវិញ ពេលនោះសមត្ថកិច្ចបានដេញតាម ឃើញដូច្នេះ ខ្លួនបានផ្ដួលម៉ូតូរត់គេច តែត្រូវបានសមត្ថកិច្ចឃាត់ខ្លួនបាន និងឆែកឆេរឃើញថ្នាំញៀនចំនួន ០១កញ្ចប់ ដែលខ្លួនទុកនៅក្នុងកញ្ចប់បារី ។ ថ្នាំញៀននោះ ខ្លួនបានពីឈ្មោះ [redacted] សំ កាលពីថ្ងៃទី០៨ ខែមីនា ឆ្នាំ២០២២ ដោយខ្លួនបានទៅសុំគ្រឿងញៀនពីឈ្មោះ [redacted] សំ យកមកប្រើប្រាស់ ។ ខ្លួនធ្លាប់ប្រើប្រាស់គ្រឿងញៀនដោយខុសច្បាប់ជាច្រើនលើកមកហើយ គឺតាំងពីឆ្នាំ២០១៨មកម្ល៉េះ ហើយប្រើប្រាស់លើកចុងក្រោយនៅថ្ងៃទី០៨ ខែមីនា ឆ្នាំ២០២២ ជាមួយឈ្មោះ [redacted] សំ ។

- ជនជាប់ចោទឈ្មោះ [redacted] សំ ហៅ នួន បានឆ្លើយថា ៖ សមត្ថកិច្ចឃាត់ខ្លួននៅថ្ងៃទី០៩ ខែមីនា ឆ្នាំ២០២២ ពេលខ្លួនកំពុងនៅក្នុងផ្ទះនៅភូមិអូរទទឹង ឃុំព្រះដាក់ ស្រុកបន្ទាយស្រី ខេត្តសៀមរាប និងបានធ្វើការឆែកឆេរដកហូតគ្រឿងញៀនចំនួន ០១កញ្ចប់ ដែលខ្លួនបានទិញពីឈ្មោះ ស្រា ភេទប្រុស អាយុ ២៥ឆ្នាំ រស់នៅភូមិតាឯក ឃុំរុនតាឯក ស្រុកបន្ទាយស្រី ខេត្តសៀមរាប កាលពីថ្ងៃទី០៨ ខែមីនា ឆ្នាំ២០២២ វេលាម៉ោងប្រហែល ០៩យប់ ក្នុងតម្លៃ ៥០,០០០(ប្រាំម៉ឺន)រៀល ។ ពេលទិញបានហើយ មិត្តភក្តិរបស់ខ្លួនឈ្មោះ សុភាត់ បានសុំពីខ្លួនទុកប្រើប្រាស់ ទើបខ្លួនបានរំលែកឲ្យខ្លះតែមិនបានលក់ដូរអ្វីទេ នៅសល់ថ្នាំញៀនខ្លះ ខ្លួនទុកប្រើប្រាស់ដោយទុកក្នុងហោប៉ៅខោ ក៏ត្រូវសមត្ថកិច្ចឃាត់ខ្លួនតែម្ដង។ កន្លងមក ខ្លួនធ្លាប់ទិញថ្នាំញៀនពីឈ្មោះ ត្រា យកមកប្រើប្រាស់ ។ នៅថ្ងៃកើតហេតុខ្លួនមិនបានលក់គ្រឿងញៀនទេ ។ សមត្ថកិច្ចដកហូតគ្រឿងញៀនចំនួន ០១កញ្ចប់ និងសម្ភារៈវេចខ្ចប់គ្រឿងញៀនមួយចំនួន។

- ជនជាប់ចោទឈ្មោះ ហេង ស្រា ហៅ ត្រា អវត្តមាននាពេលសវនាការ ។

## សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ

ក្រោយពីបានស្ដាប់ការសួរដេញដោលនាពេលសវនាការ និងការពិនិត្យឯកសារដែលមាននៅក្នុងសំណុំរឿង ជនជាប់ចោទឈ្មោះ [redacted] សុភាត់ ឬ [redacted] សុផាត់ និងឈ្មោះ [redacted] សំ បានឆ្លើយសារភាពអស់ហើយ ចំណែកឈ្មោះ [redacted] ស្រា ហៅ ត្រា មិនបានចូលខ្លួនគ្រប់ដំណាក់កាលនីតិវិធីរបស់តុលាការទាំងអស់ បើតាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] សុភាត់ ឬ [redacted] សុផាត់ និងឈ្មោះ [redacted] សំ និងភស្តុតាងដែលមាននៅក្នុងសំណុំរឿងសង្វាក់គ្នា ឃើញថា មានភស្តុតាងគ្រប់គ្រាន់ដាក់បន្ទុកលើជនជាប់ចោទ ឈ្មោះ [redacted] សុភាក់ ឬ [redacted] សុផាត់ ពីបទជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ហេតុនេះតំណាងអយ្យការស្នើសុំប្ដូរបទចោទលើជនជាប់ចោទឈ្មោះ [redacted] សុភាត់ ឬ [redacted] សុផាត់ ពីបទរក្សាទុក និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ទៅបទ ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀនជំនួសវិញ ។ ឯជនជាប់ចោទឈ្មោះ [redacted] ស្រា និងជនជាប់ចោទឈ្មោះ [redacted] សំ តំណាងអយ្យការស្នើសុំតម្កល់បទចោទប្រកាន់តាមដីកាសន្និដ្ឋានស្ថាពរលេខ៣០៨អយក/២២ ចុះថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០២២ ទុកជាបានការដដែល ព្រមទាំងប្ដឹងសុំឲ្យចៅក្រមជំនុំជម្រះចេញដីកាបង្គាប់ឲ្យចាប់ខ្លួនឈ្មោះ [redacted] ស្រា ហៅ ត្រា និងប្ដឹងសុំឲ្យតុលាការសម្រេចផ្ដន្ទាទោសជនជាប់ចោទទៅតាមច្បាប់ ។

## សេចក្តីសន្និដ្ឋានរបស់លោកស្រី [redacted] ជាមេធាវីការពារសិទ្ធិ ឲ្យជនជាប់ចោទឈ្មោះ [redacted] សុភាត់

ឆ្លងតាមការស្តាប់ចម្លើយនានាពេលសវនាការនេះឃើញថា កូនក្តីខ្លួនបានទទួលកំហុសសារភាពនូវទង្វើប្រព្រឹត្តរបស់ខ្លួន ហើយពុំបង្កការលំបាកដល់ការស៊ើបសួររបស់តុលាការទេ ហេតុនេះ សូមតុលាការមេត្តាផ្តល់ស្ថានសម្រាលទោសដល់កូនក្តីខ្លួន ដោយអនុគ្រោះ ។

## សំដីចុងក្រោយរបស់ជនជាប់ចោទ

- ជនជាប់ចោទឈ្មោះ [redacted] សុភាត់ ឬ [redacted] សុផាត់ ហៅ យួន បាននិយាយសំដីចុងក្រោយបង្ហស់ថា ៖ សូមតុលាការមេត្តាជួយសម្រាលទោសដល់ខ្លួនដោយអនុគ្រោះ ។
- ជនជាប់ចោទឈ្មោះ [redacted] សំ ហៅ នួន បាននិយាយសំដីចុងក្រោយបង្ហស់ថា ៖ សូមតុលាការមេត្តាជួយសម្រាលទោសដល់ខ្លួនដោយអនុគ្រោះ ។

ក្រោយពីបាន ស្តាប់ចម្លើយរបស់ជនជាប់ចោទ

ក្រោយពីបាន ស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ

ក្រោយពីបាន ស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ

ក្រោយពីបាន ស្តាប់សំណូមពរចុងក្រោយរបស់ជនជាប់ចោទ

ក្រោយពីបាន ពិនិត្យ និងពិចារណាត្រឹមត្រូវតាមច្បាប់

## សំអាងហេតុ

១- តុលាការបានទទួលជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ ៣២៣ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០២២ តាមដីកាដំណោះស្រា លេខៈ ២១៩៥ (ឋ)/២២ ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ២០២២ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តសៀមរាប ដែលបានបញ្ជូនជនជាប់ចោទ៖

ក-ឈ្មោះ [redacted]សុភាត់ ហៅ យួន ភេទប្រុស អាយុ២៤ឆ្នាំ ជនជាតិខ្មែរ និងឈ្មោះ [redacted] សំ ហៅ នួន ភេទប្រុស អាយុ២៣ឆ្នាំ ជនជាតិខ្មែរ មកជំនុំជម្រះពីបទ រក្សាទុក និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិតាកុះ ឃុំព្រះដាក់ ស្រុកបន្ទាយស្រី ខេត្តសៀមរាប កាលពីថ្ងៃទី០៩ ខែមីនា ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៤០ និងមាត្រា៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

ខ-ឈ្មោះ [redacted] ស្រា ហៅ ត្រា ភេទប្រុស អាយុ២២ឆ្នាំ ជនជាតិខ្មែរ មកជំនុំជម្រះពីបទ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិតាកុះ ឃុំព្រះដាក់ ស្រុកបន្ទាយស្រី ខេត្តសៀមរាប កាលពីថ្ងៃទី០៨ ខែមីនា ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

២- តាមរបាយការណ៍សំយោគលេខ ២៤៦/២២ ប្រ.គ្រ.៣ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០២២ របស់ការិយាល័យប្រឆាំងគ្រឿងញៀន នៃស្នងការដ្ឋាននគរបាលខេត្តសៀមរាប បានសន្និដ្ឋានថា បទល្មើសដែលបានរៀបរាប់ខាងលើនេះ គឺពិតជាបទល្មើសព្រហ្មទណ្ឌដែលបានកើតឡើង ហើយមានចែងនៅក្នុងមាត្រា៤០ និងមាត្រា៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន បទ ដឹងជញ្ជូន និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន គឺបង្កឡើងដោយឈ្មោះ [redacted] សុភាត់ ហៅ យួន ,បទ រក្សាទុក ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន គឺបង្កឡើងដោយឈ្មោះ [redacted] សំ ហៅ នួន និងបទ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន គឺបង្កឡើងដោយឈ្មោះ [redacted] ស្រា ហៅ ត្រា ។



Scanned with CamScanner

៣- តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] សុភាត់ ឬ [redacted] សុផាត់ ហៅ យួន និងឈ្មោះ [redacted] សំ ហៅ នួន បានឆ្លើយនាពេលសវនាការ ជនជាប់ចោទទាំងពីរនាក់បានឆ្លើយសារភាពហើយសកម្មភាពរបស់ជនជាប់ចោទទាំងពីរនាក់អាចឲ្យតុលាការជឿបានថា ជនជាប់ចោទពិតជាបានប្រព្រឹត្តបទល្មើសដូចការចោទប្រកាន់ប្រាកដមែន ហើយចម្លើយនេះមានភាពស៊ីសង្វាក់ទៅនឹងចម្លើយរបស់ជនជាប់ចោទនៅដំណាក់មន្ត្រីនគរបាលយុត្តិធម៌ ,ដំណាក់កាលអយ្យការ និងដំណាក់កាលចៅក្រមស៊ើបសួរ ព្រមទាំងអង្គហេតុ ,កស្តុតាងដែលបានដកហូតជាក់ស្តែងពីជនជាប់ចោទ និងឯកសារនានាដែលមាននៅក្នុងសំណុំរឿងនាំឲ្យកំណត់បានថា អំពើរបស់ជនជាប់ចោទឈ្មោះ [redacted] សុភាត់ ឬ [redacted] សុផាត់ ហៅ យួន គឺជាបទល្មើសជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន រីឯឈ្មោះ [redacted] សំ ហៅ នួន គឺជាបទល្មើសរក្សាទុក និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ពិតប្រាកដមែន។

៤- ជនជាប់ចោទឈ្មោះ [redacted] ស្រា ហៅ ត្រា មិនបានចូលមកឆ្លើយបំភ្លឺ និងបង្ហាញកស្តុតាងដោះបន្ទុកមកតុលាការនោះទេ ម៉្យាងទៀតបើផ្អែកតាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] សំ ហៅ នួន ថា ថ្នាំញៀនដែលសមត្ថកិច្ចដកហូត ចំនួន ០១កញ្ចប់ គឺទិញពីឈ្មោះ ស្រា ភេទប្រុស អាយុ ២៥ឆ្នាំ រស់នៅភូមិតាឯក ឃុំរុនតាឯក ស្រុកបន្ទាយស្រី ខេត្តសៀមរាប កាលពីថ្ងៃទី០៨ ខែមីនា ឆ្នាំ២០២២ វេលាម៉ោងប្រហែល ០៩យប់ ក្នុងតម្លៃ ៥០,០០០(ប្រាំម៉ឺន)រៀល ។ ផ្អែកតាមចម្លើយជនជាប់ចោទឈ្មោះ [redacted] សំ ហៅ នួន អាចឲ្យតុលាការសន្និដ្ឋានបានថា ជនជាប់ចោទឈ្មោះ [redacted] ស្រា ហៅ ត្រា ពិតជាបានប្រព្រឹត្តបទល្មើសជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ដូចការបញ្ជូនសំណុំរឿងមកជំនុំជម្រះរបស់ចៅក្រមស៊ើបសួរពិតប្រាកដមែន ។

៥- តាមសេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការនាពេលសវនាការថា ជនជាប់ចោទឈ្មោះ [redacted] សុភាត់ ឬ [redacted] សុផាត់ និងឈ្មោះ [redacted] សំ បានឆ្លើយសារភាពអស់ហើយ ចំណែកឈ្មោះ [redacted] ស្រា ហៅ ត្រា មិនបានចូលខ្លួនគ្រប់ដំណាក់កាលនីតិវិធីរបស់តុលាការទាំងអស់ បើតាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] សុភាត់ ឬ [redacted] សុផាត់ និងឈ្មោះ [redacted] សំ និងកស្តុតាងដែលមាននៅក្នុងសំណុំរឿងសង្វាក់គ្នាឃើញថា មានកស្តុតាងគ្រប់គ្រាន់ដាក់បន្ទុកលើជនជាប់ចោទ ឈ្មោះ [redacted] សុភាក់ ឬ [redacted] សុផាត់ ពីបទជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ហេតុនេះតំណាងអយ្យការស្នើសុំប្តូរបទចោទលើជនជាប់ចោទឈ្មោះ [redacted] សុភាត់ ឬ [redacted] សុផាត់ ពីបទរក្សាទុក និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ទៅបទជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀនជំនួសវិញ ។ រីឯជនជាប់ចោទឈ្មោះ [redacted] ស្រា និងជនជាប់ចោទឈ្មោះ [redacted] សំ តំណាងអយ្យការស្នើសុំតម្កល់បទចោទប្រកាន់តាមដីកាសន្និដ្ឋានស្ថាពរលេខ ៣០៨អយក/២២ ចុះថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០២២ ទុកជាបានការដដែល ព្រមទាំងប្តឹងសុំឲ្យចៅក្រមជំនុំជម្រះចេញដីកាបង្គាប់ឲ្យចាប់ខ្លួនឈ្មោះ [redacted] ស្រា ហៅ ត្រា និងប្តឹងសុំឲ្យតុលាការសម្រេចផ្តន្ទាទោសជនជាប់ចោទទៅតាមច្បាប់ ។ គប្បីតុលាការលើកយកការសន្និដ្ឋានរបស់តំណាងអយ្យការមកពិចារណាក្នុងការសម្រេចសេចក្តី ។

៦- តាមកំណត់ហេតុទទួល ស្គាល់សម្ភារៈ និងវត្ថុតាង លេខ ២៤៩/២២ ក.ណ.ហ ចុះថ្ងៃទី០៩ ខែមីនា ឆ្នាំ២០២២ របស់ការិយាល័យប្រឆាំងគ្រឿងញៀន នៃស្នងការដ្ឋាននគរបាលខេត្តសៀមរាប បាន

បញ្ជាក់ថា ម្សៅក្រាម ពណ៌សថ្លា ចំនួន មួយកញ្ចប់ ជាគ្រឿងញៀនខុសច្បាប់ប្រភេទមេតំហ្វេតាមីន ពិតជារបស់ឈ្មោះ [redacted] សុភាត់ និងម្សៅក្រាមពណ៌សថ្លាចំនួន មួយកញ្ចប់ ពិតជារបស់ឈ្មោះ [redacted] សំ ប្រាកដមែន។

៧- តាមកំណត់ហេតុធ្វើតេស្ត ថ្លឹង និងវេចខ្ចប់វត្ថុតាង លេខ ២៥០/២២ ក.ណ.ហ ចុះថ្ងៃទី០៩ ខែមីនា ឆ្នាំ២០២២ របស់ការិយាល័យប្រឆាំងគ្រឿងញៀន នៃស្នងការដ្ឋាននគរបាលខេត្តសៀមរាប បានបញ្ជាក់ថា បានយកសំណាកសារធាតុដែលមានតម្រុយថា គ្រឿងញៀនខុសច្បាប់ដែលមានចំនួន ០១កញ្ចប់ វេចខ្ចប់ដោយថ្លឹងនឹងជញ្ជីងម៉ាក DIGITAL៨០២៨ មានទម្ងន់សរុបចំនួន ០,៤៤ក្រាម (ទម្ងន់សុទ្ធ) ជារបស់ឈ្មោះ [redacted] សំ និងបានយកសំណាកសារធាតុដែលមានតម្រុយថា គ្រឿងញៀនខុសច្បាប់ដែលមានចំនួន ០១កញ្ចប់ វេចខ្ចប់ដោយថ្លឹងនឹងជញ្ជីងម៉ាក DIGITAL៨០២៨ មានទម្ងន់សរុបចំនួន ០,០១ក្រាម (ទម្ងន់សុទ្ធ) ជារបស់ឈ្មោះ [redacted] សុភាត់ ។

៨- តាមកំណត់ហេតុធ្វើតេស្តស្វែងរកសារធាតុញៀនលេខៈ ២៥១/២២ ក.ណ.ហ ចុះថ្ងៃទី០៩ ខែមីនា ឆ្នាំ២០២២ របស់ការិយាល័យប្រឆាំងគ្រឿងញៀន នៃស្នងការដ្ឋាននគរបាលខេត្តសៀមរាប បានបញ្ជាក់ថា បានធ្វើតេស្តទឹកនោមលើឈ្មោះ [redacted] សុភាត់ និងឈ្មោះ [redacted] សំ ជាលទ្ធផល គឺវិជ្ជមាន (តម្រុយមេតំហ្វេតាមីន) ។

៩- សកម្មភាពរបស់ជនជាប់ចោទឈ្មោះ [redacted] សុភាត់ ឬ [redacted] សុផាត់ ហៅ យួន ត្រូវបានកំណត់ថា ជាបទល្មើស ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ហើយបញ្ញត្តិឲ្យផ្តន្ទាទោសនៅក្នុងមាត្រា៤០ កថាខណ្ឌទី៣,៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ដាក់ពន្ធនាគារពី ២(ពីរ)ឆ្នាំទៅ ៥(ប្រាំ)ឆ្នាំ និងអាចពិន័យជាប្រាក់ពី៤.០០០.០០០(បួនលាន)រៀលទៅ១០.០០០.០០០(ដប់លាន) រៀល និងបានប្រើប្រាស់ថ្នាំញៀន ត្រូវបានច្បាប់កំណត់ថា ជាបទល្មើស ប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន បញ្ញត្តិឲ្យផ្តន្ទាទោសនៅក្នុងមាត្រា៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ដាក់ពន្ធនាគារពី ១(មួយ)ខែ ទៅ ៦(ប្រាំមួយ) ខែ និងអាចពិន័យជាប្រាក់ពី ១០០.០០០ (មួយសែន) រៀល ទៅ ១.០០០.០០០ (មួយលាន)រៀល។

១០- សកម្មភាពរបស់ជនជាប់ចោទឈ្មោះ [redacted] សំ ហៅ នួន ត្រូវបានច្បាប់កំណត់ថា ជាបទល្មើស រក្សាទុកដោយខុសច្បាប់នូវសារធាតុញៀន ហើយបញ្ញត្តិឲ្យផ្តន្ទាទោសនៅក្នុងមាត្រា៤០ កថាខណ្ឌទី១,៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំទៅ ៥ (ប្រាំ) ឆ្នាំ និងអាចពិន័យជាប្រាក់ពី ៤.០០០.០០០ (បួនលាន) រៀល ទៅ ១០.០០០.០០០(ដប់លាន)រៀល និងបានប្រើប្រាស់ថ្នាំញៀន ត្រូវបានច្បាប់កំណត់ថាជាបទល្មើស ប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន បញ្ញត្តិឲ្យផ្តន្ទាទោសនៅក្នុងមាត្រា៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ដាក់ពន្ធនាគារពី ១(មួយ)ខែ ទៅ ៦(ប្រាំមួយ) ខែ និងអាចពិន័យជាប្រាក់ពី ១០០.០០០ (មួយសែន) រៀល ទៅ ១.០០០.០០០ (មួយលាន)រៀល។

១១-សកម្មភាពរបស់ជនជាប់ចោទឈ្មោះ [redacted] ស្រា ហៅ ត្រា ត្រូវបានច្បាប់កំណត់ថា ជាបទល្មើស ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ហើយបញ្ញត្តិឲ្យផ្តន្ទាទោសនៅក្នុងមាត្រា៤០ កថាខណ្ឌទី៣,៤នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ដាក់ពន្ធនាគារពី ២(ពីរ)ឆ្នាំទៅ ៥(ប្រាំ) ឆ្នាំ និងអាចពិន័យជាប្រាក់ពី ៤.០០០.០០០(បួនលាន)រៀល ទៅ ១០.០០០.០០០(ដប់លាន)រៀល ។



Scanned with CamScanner

១២- អំពើរបស់ជនជាប់ចោទធ្វើឲ្យប៉ះពាល់ដល់សន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ របៀបរៀបរយល្អក្នុងសង្គមដែលច្បាប់ហាមឃាត់ ជាពិសេសបានបំពានទៅនឹងមាត្រាមាត្រា៤០ កថាខណ្ឌទី១ ទី៣ និងទី៤ និងមាត្រា៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

១៣- ជនជាប់ចោទ ជានីតិជន ដែលមានសមត្ថភាពស្មារតីគ្រប់គ្រាន់ក្នុងការទទួលខុសត្រូវចំពោះអំពើរបស់ខ្លួនដែលបានប្រព្រឹត្ត ។

១៤- មានបន្ទុក និងភស្តុតាងគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] សុកាត់ ឬ [redacted] សុផាត់ ហៅ យួន ភេទប្រុស អាយុ២៤ឆ្នាំ ជនជាតិខ្មែរ ពីបទ ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិតាកុះ ឃុំព្រះដាក់ ស្រុកបន្ទាយស្រី ខេត្តសៀមរាប កាលពីថ្ងៃទី០៩ ខែមីនា ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៤០ កថាខណ្ឌទី៣ និងទី៤ និងមាត្រា៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

១៥- មានបន្ទុក និងភស្តុតាងគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] សំ ហៅ នួន ភេទប្រុស អាយុ២៣ឆ្នាំ ជនជាតិខ្មែរ ពីបទ រក្សាទុក និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិតាកុះ ឃុំព្រះដាក់ ស្រុកបន្ទាយស្រី ខេត្តសៀមរាប កាលពីថ្ងៃទី០៩ ខែមីនាឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៤០ កថាខណ្ឌទី១ និងទី៤ និងមាត្រា៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

១៦- មានបន្ទុក និងភស្តុតាងគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] ស្រា ហៅ ត្រា ភេទប្រុស អាយុ ២២ឆ្នាំ ជនជាតិខ្មែរ ពីបទ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិតាកុះ ឃុំព្រះដាក់ ស្រុកបន្ទាយស្រី ខេត្តសៀមរាប កាលពីថ្ងៃទី០៨ ខែមីនា ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៤០ កថាខណ្ឌទី៣ និងទី៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

១៧- ជនជាប់ចោទឈ្មោះ [redacted] ស្រា ហៅ ត្រា បានរត់គេចខ្លួន ក្រោយពីប្រព្រឹត្តបទល្មើសរួច ហើយម៉្យាងទៀតតុលាការនឹងប្រកាសផ្តន្ទាទោសជនជាប់ចោទដាក់ពន្ធនាគារ ១(មួយ)ឆ្នាំយ៉ាងតិច ដោយគ្មានការព្យួរទេ ដូចនេះ តាមបញ្ញត្តិមាត្រា៣៥៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ តាមសេចក្តីសម្រេចពិសេសតុលាការគប្បីចេញនៅក្នុងពេលសវនាការនូវដីកាបង្គាប់ឲ្យចាប់ខ្លួនជនជាប់ចោទអវត្តមាន។

១៨- វត្ថុចាប់យកដូចមានក្នុងដីកាបង្គាប់ឲ្យរក្សាទុកវត្ថុតាងដែលចាប់យកលេខៈ ១០៣/២២ ចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ២០២២ របស់សាលាដំបូងខេត្តសៀមរាប មានដូចជា ៖

ក- ស្រោមសំបុត្របិទជិតពណ៌ខ្លីមខ្ចី មានស្នាមមេដៃរបស់ឈ្មោះ [redacted] សុកាត់ ចំនួន ០១(មួយ)។

គឺជាវត្ថុតាង នៃបទល្មើស ដូចនេះ តុលាការសម្រេចរឹបអូសតាមមាត្រា៦២ ,មាត្រា៦៣ នៃក្រមព្រហ្មទណ្ឌ និងមាត្រា៩៣ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

ខ- ម៉ូតូម៉ាក HONDA DREAM ស៊េរីឆ្នាំ២០០៧ ឡើងតែម២០១៥ បិតស្កុតពណ៌ក្រហម ពាក់ផ្លាកលេខ បន្ទាយមានជ័យ 1L-4431 លេខតួរ 8191542 (មានកញ្ចក់ខាងឆ្វេង អត់ខាងស្តាំ អត់កន្ត្រកមានកាំបន្ទះខ្មៅ អត់សោ) ចំនួន ០១គ្រឿង ។

គឺជាទ្រព្យសម្បត្តិផ្ទាល់ខ្លួន មិនមែនវត្ថុតាងនៃបទល្មើសទេ ដូចនេះ តុលាការគប្បីសម្រេចប្រគល់វត្ថុចាប់យកឲ្យទៅម្ចាស់ដើមវិញ តាមមាត្រា៣៥៤នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

## ហេតុដូច្នេះ សម្រេច

១/- កែប្រែបទចោទប្រកាន់លើឈ្មោះ [redacted] សុភាត់ ឬ [redacted] សុផាត់ ហៅ ឃួន ភេទប្រុស ថ្ងៃខែឆ្នាំកំណើត ០៥.១២.១៩៩៧ ជនជាតិខ្មែរ ពីបទ **រក្សាទុកដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅភូមិតាកុះ ឃុំព្រះដាក់ ស្រុកបន្ទាយស្រី ខេត្តសៀមរាប កាលពីថ្ងៃទី០៩ ខែមីនា ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៤០ កថាខណ្ឌទី១ និងទី៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន មកបទ **ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅភូមិតាកុះ ឃុំព្រះដាក់ ស្រុកបន្ទាយស្រី ខេត្តសៀមរាប កាលពីថ្ងៃទី០៩ ខែមីនា ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៤០ កថាខណ្ឌទី៣ និងទី៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

**២/- ផ្តន្ទាទោស:**

ក-ឈ្មោះ [redacted] **សុភាត់ ឬ** [redacted] **សុផាត់ ហៅ ឃួន** ភេទប្រុស ថ្ងៃខែឆ្នាំកំណើត ០៥.១២.១៩៩៧ ជនជាតិខ្មែរ ដាក់ពន្ធនាគារកំណត់ **២(ពីរ)ឆ្នាំ ៨(ប្រាំបី)ខែ** និងពិន័យជាប្រាក់ចំនួន ៤.០០០.០០០ (**បួនលាន**)រៀល តែទោសពិន័យនេះត្រូវអនុវត្តចំនួន **២.០០០.០០០ (ពីរលាន)រៀល** ទោសពិន័យនៅសល់ពីនេះត្រូវព្យួរធម្មតា ។

ពីបទ **ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅភូមិតាកុះ ឃុំព្រះដាក់ ស្រុកបន្ទាយស្រី ខេត្តសៀមរាប កាលពីថ្ងៃទី០៩ ខែមីនា ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៤០ កថាខណ្ឌទី៣ និងទី៤ និងមាត្រា៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និងមាត្រា១០៧ ,មាត្រា១០៨ នៃក្រមព្រហ្មទណ្ឌ ។

ខ-ឈ្មោះ [redacted] **សំ ហៅ នួន** ភេទប្រុស ឆ្នាំកំណើត១៩៩៩ ជនជាតិខ្មែរ ដាក់ពន្ធនាគារកំណត់ **២(ពីរ)ឆ្នាំ ១០(ដប់)ខែ** និងពិន័យជាប្រាក់ចំនួន **៤.០០០.០០០ (បួនលាន)រៀល** តែទោសពិន័យនេះត្រូវអនុវត្តចំនួន **២.០០០.០០០ (ពីរលាន)រៀល** ទោសពិន័យនៅសល់ពីនេះត្រូវព្យួរធម្មតា ។

ពីបទ **រក្សាទុក និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅភូមិតាកុះ ឃុំព្រះដាក់ ស្រុកបន្ទាយស្រី ខេត្តសៀមរាប កាលពីថ្ងៃទី០៩ ខែមីនា ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៤០ កថាខណ្ឌទី១ និងទី៤ និងមាត្រា៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និងមាត្រា១០៧ ,មាត្រា១០៨ នៃក្រមព្រហ្មទណ្ឌ ។

គ-ឈ្មោះ [redacted] **ស្រា ហៅ ត្រា** ភេទប្រុស អាយុ ២២ឆ្នាំ ជនជាតិខ្មែរ ដាក់ពន្ធនាគារកំណត់ **៣(បី)ឆ្នាំ និងពិន័យជាប្រាក់ចំនួន ៦.០០០.០០០ (ប្រាំមួយលាន)រៀល** ។

ពីបទ **ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅភូមិតាកុះ ឃុំព្រះដាក់ ស្រុកបន្ទាយស្រី ខេត្តសៀមរាប កាលពីថ្ងៃទី០៨ ខែមីនា ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៤០ កថាខណ្ឌទី៣ និងទី៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។



Scanned with CamScanner

៣/- ចេញដីកាបង្គាប់ឲ្យចាប់ខ្លួនឈ្មោះ [redacted] ស្រា ហៅ ត្រា ដើម្បីយកមកអនុវត្តទោសតាមអំណាចនៃសាលក្រមនេះ ។ តាមមាត្រា៣៥៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

៤/-វត្ថុចាប់យកដូចមានក្នុងដីកាបង្គាប់ឲ្យរក្សាទុកវត្ថុតាងដែលចាប់យកលេខៈ ១០៣/២២ ចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ២០២២ របស់សាលាដំបូងខេត្តសៀមរាប មានដូចជា ៖

ក- ស្រោមសំបុត្របិទជិតពណ៌ខ្លឹមខ្នុរ មានស្នាមដៃរបស់ឈ្មោះ [redacted] សុកាត់ ចំនួន ០១(មួយ)។

**សម្រេចរឹបអូស** តាមមាត្រា ៦២ ,មាត្រា ៦៣ នៃក្រមព្រហ្មទណ្ឌ និងមាត្រា ៩៣ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

ខ- ម៉ូតូម៉ាក HONDA DREAM សេរីឆ្នាំ២០០៧ ឡើងតែម២០១៥ បិតស្កុតពណ៌ក្រហម ពាក់ផ្លាកលេខ បន្ទាយមានជ័យ 1L-4431 លេខតួរ 8191542 (មានកញ្ចក់ខាងឆ្វេង អត់ខាងស្តាំ អត់កន្ត្រក មានកាំបន្ទះខ្មៅ អត់សោ) ចំនួន ០១គ្រឿង ។

**សម្រេចប្រគល់វត្ថុចាប់យកឲ្យទៅម្ចាស់ដើមវិញ** តាមមាត្រា៣៥៤នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

៥/- សាលក្រមនេះជំនុំជម្រះ នៅថ្ងៃទី ០៥ ខែ កក្កដា ឆ្នាំ ២០២២ និងប្រកាសជាសាធារណៈ នៅថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ២០២២ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] សុកាត់ ឬ [redacted] សុផាត់ ហៅ យួន ,ឈ្មោះ [redacted] សំ ហៅ នួន និងកំបាំងមុខជនជាប់ចោទឈ្មោះ [redacted] ស្រា ហៅ ត្រា ។

ទុកសិទ្ធិប្តឹងទាស់ និងប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

| **ក្រឡាបញ្ជីសវនាការ** | **ចៅក្រមជំនុំជម្រះ** |
|---|---|
| ហត្ថលេខា និងត្រា [redacted] | ហត្ថលេខា និងត្រា [redacted] |

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃ ពុធ ៧រោច ខែអាសាឍ ឆ្នាំខាល ចត្វាស័ក ព.ស២៥៦៦

សៀមរាប , ថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០២២

| បានឃើញ<br>**ចៅក្រមជំនុំជម្រះ** | **ក្រឡាបញ្ជី** |
|---|---|
| [redacted] | [redacted] |

បានថតចម្លងត្រឹមត្រូវចេញពី

ច្បាប់ដើមដោយម៉ាស៊ីនហ្វូតូកូពី

សៀមរាប ថ្ងៃទី០៤ ខែ តុលា ឆ្នាំ២០២២

**ក្រឡាបញ្ជី**

[redacted]